# ធានារ៉ាប់រង ការរក្សាសុខភាព

## សំរាប់ពលរដ្ឋដែលមានប្រាក់ចំណូល ឬ ធនធានតិច

## ពាក្យសុំ

# MEDI-CAL

## ពាក្យសុំ សម្រាប់ផ្ញើតាមប៉ុស្តិ៍ និង ការណែនាំអំពីរបៀបបំពេញ




**បើត្រូវការជំនួយក្នុងការសុំ Medi-Cal ដោយ *មិនបាច់បង់ប្រាក់***
**សូមទាក់ទង មកមន្ទីរសង្គមកិច្ច (Welfare Office) នៅជិតអ្នក**

## អ្វីទៅហៅថា Medi-Cal ?

- ការធានារក្សាសុខភាព សំរាប់អ្នកដែលមានសិទ្ធិទទួល រស់នៅក្នុងរដ្ឋកាលីហ្វ័ញ៉ា ហើយមានប្រាក់ចំណូល ឬធនធានតិចជាងកំរិតដែលកំណត់។

## ជនណាដែលអាចទទួល Medi-Cal ?



- អ្នកដែលមានអាយុ 65 ឬច្រើនជាង
- អ្នកដែលមានអាយុ 21 ឬតិចជាង
- អ្នកដែលមានអាយុ 21 ដល់ 65 បើសិនជាមានក្មេងមិនទាន់ពេញច្បាប់រស់នៅជាមួយ
- អ្នកដែលពិការភ្នែក ឬ ពិការដៃជើង
- ស្ត្រីមានផ្ទៃពោះ
- អ្នកដែលស្នាក់នៅកន្លែងថែរក្សាអ្នកជម្ងឺរយៈពេលវែង
- ជនភៀសខ្លួន អ្នកសុំសិទ្ធិជ្រកកោន ឬ Cuban/Haitian Entrants

## តើខ្ញុំចាំបាច់ជាជនជាតិ អាមេរិច ឬ ទើបអាចទទួល Medi-Cal ?

- ទេ អាណិកជនដែលមានក្រដាសស្នាមក្តី គ្មានក្រដាសស្នាមក្តីអាចមាន សិទ្ធិទទួល Medi-Cal ។ អ្នកខ្លះទទួលបានតែផលប្រយោជន៍ដែលទាក់ទង និងការមានផ្ទៃពោះ ឬ ជម្ងឺអាសន្នតែប៉ុណ្ណោះ ។ តែ អ្នកខ្លះទៀត អាចទទួលផលប្រយោជន៍ទាំងអស់របស់ Medi-Cal ស្រេចតែស្ថានភាព ឬ ឋានៈតាមច្បាប់ របស់អាណិកជននោះ ។

## ពេលដែល Medi-Cal ប្រើពាក្យ “ក្មេងមិនទាន់ពេញច្បាប់” តើមានន័យដូចម្តេច ?

- គឺជា ក្មេង ដែលមានគូរស្រករ ឬ អត់គូរស្រករ អាយុតិចជាង 21 ឆ្នាំ រស់នៅជាមួយអ្នក ឬនៅឯសាលារៀន ឆ្ងាយពីផ្ទះ ។

## តើ ខ្ញុំត្រូវធ្វើដូចម្តេចដើម្បីបានទទួល Medi-Cal ?

- បំពេញ ហើយដាក់ផ្ញើរ តាមប៉ុស្ត៍ នូវពាក្យសុំ ដែលមានភ្ជាប់ជាមួយនេះ
- ផ្ញើរភ្ជាប់ជាមួយនោះ នូវឯកសារដែលត្រូវការ (សូមអានរបៀបបំពេញ)



## តើ ខ្ញុំនិងគ្រួសារអាចទទួលផលប្រយោជន៍របស់ Medi-Cal តាមរបៀបណា ?

បើសិនអ្នកជាមនុស្សដែលនៅក្នុងក្រុម “ជនណាដែលអាចទទួល Medi-Cal” ខាងលើ:

- យើងនឹងពិនិត្យមើលប្រាក់ចំណូល ហើយដកចេញប្រាក់ចំណាយ ដើម្បីសម្រេចយកចំនួនដែលប្រើក្នុងការឲ្យ Medi-Cal ។
- យើងពិនិត្យមើលអ្វីដែលគ្រួសារអ្នកមាន (បញ្ជីប្រាក់នៅធនាគារ ឡាន ជាដើម) ដើម្បីឲ្យដឹងថាអ្នកពិតជាស្ថិតនៅក្នុងកំរិតធនធានដែលបានកំណត់ ។ **សូមបញ្ជាក់ថា :** គេមិនរាប់បញ្ចូលនូវអ្វីៗទាំងអស់ដែលអ្នកមាន ទៅក្នុងរបៀបគិតគូរនេះទេ ហើយមន្ទីរសង្គមកិច្ចនៅជិតអ្នកអាចផ្តល់ពត៌មានពិស្តាបាន ។

## បើខ្ញុំមិនមែននៅក្នុងក្រុមណាមួយដែលអាចទទួល ផលប្រយោជន៍ នោះបាន តើខ្ញុំត្រូវធ្វើដូចម្តេច អាចទទួលផលប្រយោជន៍ នេះ ?

- សូមទាក់ទង មន្ទីរសង្គមកិច្ចជិតអ្នក ដើម្បីបានពត៌មាន អំពី កិច្ចបំរើការរបស់ medical ខោនធី (County) របស់អ្នក ។

# នៅពេលដែលខ្ញុំ ដាក់ពាក្យសុំ ការធានាសុខភាព Medi-Cal

## តើខ្ញុំត្រូវធ្វើដូចម្តេច បើ .....

### ខ្ញុំត្រូវការចាំបាច់ដើម្បី ទទួលការព្យាបាលជាបន្ទាន់ ឬមានផ្ទៃពោះ ។

• យកពាក្យសុំនេះទៅ មន្ទីរសង្គមកិច្ចជិតអ្នកដោយផ្ទាល់ ដើម្បីចាប់ផ្តើមសុំជាបន្ទាន់ ។

### ខ្ញុំមានពាក្យសុំ ប៉ុន្តែត្រូវការគេឲ្យជួយបំពេញ ។

• អានរបៀបបំពេញ ឲ្យបានច្បាស់លាស់

• សូមទាក់ទង មកមន្ទីរសង្គមកិច្ច (Welfare Office) នៅជិតអ្នកឲ្យជួយ

• រកមិត្តភ័ក្តិ ឬបងប្អូន ឲ្យជួយបំពេញ




### ខ្ញុំនិង ប្រពន្ធ (ឬប្តី)ខ្ញុំ កំពុងចូលទៅក្នុង ណើស៊ីងហូម (Nursing Home) ហើយកំពុងដាក់ពាក្យសុំ Medi-Cal ។

• ត្រូវទាក់ទងទៅ មន្ទីរសង្គមកិច្ចជិតអ្នក ជាបន្ទាន់ដើម្បីសុំក្រដាសបំពេញ ផ្លាស់ប្តូរ ស្ថានភាពទទួល Medi-Cal គំរូលេខ DHCS 7077 ។ ក្រដាសបំពេញនេះអាច ពន្យល់អំពីធនធានខ្លះដែលមិនរាប់បញ្ចូល ករណីការពារខ្លះដែលជួយមិនធ្វើឲ្យ ប្តីឬប្រពន្ធក្រ និងស្ថានភាពខ្លះដែលអាចធ្វើឲ្យការផ្លាស់ប្តូរឈ្មោះជាម្ចាស់ផ្ទះមិនប៉ះពាល់ដល់សិទ្ធិទទួល Medi-Cal ។

### ខ្ញុំបំពេញក្រដាសពាក្យសុំ ហើយចង់ដាក់ផ្ញើរតាមប៉ុស្តិ៍

• ផ្ញើក្រដាសពាក្យសុំដែលបំពេញហើយ ព្រមទាំងឯកសារដែលទាក់ទង មកកាន់មន្ទីរសង្គមកិច្ចនៅជិតអ្នក។

កំណត់សំគាល់៖ កម្មវិធី Medi-Cal នឹងបង់ប្រាក់សម្រាប់តែសេវាកម្មដ៏ធានារ៉ាប់រងដែលអ្នកទទួលពីអ្នកផ្តល់សេវាកម្មសុខភាព Medi-Cal ក្រោយពីអ្នកដាក់ពាក្យសុំប៉ុណ្ណោះ។ បើលោកអ្នកចង់ឲ្យ កម្មវិធី Medi-Cal បង់ប្រាក់ឲ្យ នោះសូមបញ្ជាក់ថាអ្នកផ្តល់សេវាកម្មសុខភាពរបស់អ្នក គឺជាអ្នកផ្តល់សេវាកម្មដែលចុះឈ្មោះក្នុងកម្មវិធី Medi-Cal។

### ខ្ញុំគ្មានទីជម្រក ឬ ខ្ញុំគ្មានអសយដ្ឋានទទួលសំបុត្រតាមប៉ុស្តិ៍

**កុំផ្ញើរពាក្យសុំនេះ**

• ទៅកាន់ មន្ទីរសង្គមកិច្ចជិតអ្នក ហើយដាក់ពាក្យសុំនេះ

### ខ្ញុំជាក្មេងមិនទាន់ពេញច្បាប់ ហើយត្រូវការ ការរក្សាការសំងាត់ សំរាប់ការមិនឲ្យមានកូន ការថែររក្សាផ្ទៃពោះ ជម្ងឺខួរក្បាល ការព្យាបាលនិងឲ្យយោបល់ចំពោះរោគញៀនគ្រឿងញៀន និងគ្រឿងស្រវឹង ជម្ងឺឆ្លងតាមផ្លូវភេទ (STD) ឬ ការរំលោភផ្លូវភេទ

• ដើម្បីរក្សាការសំងាត់នេះឲ្យបានល្អ អ្នកត្រូវតែយកពាក្យសុំនេះទៅកាន់មន្ទីរ សង្គមកិច្ចជិតអ្នកឬ កន្លែងដែលមានអ្នកធ្វើការរបស់ក្រសួងសង្គមកិច្ច ។

**កុំផ្ញើរពាក្យសុំនេះ**

### ខ្ញុំចង់សុំ Medi-Cal ដោយផ្ទាល់ ហើយមិនចង់ផ្ញើរពាក្យសុំនេះតាមប៉ុស្តិ៍ទេ

• ទាក់ទង មន្ទីរសង្គមកិច្ចជិតអ្នក ហើយស្នើរជួបសម្ភាសសុំដោយផ្ទាល់ ។

ត្រូវចាំថា ទោះបីអ្នកយកពាក្យសុំនេះទៅ មន្ទីរសង្គមកិច្ចជិតអ្នក ដោយផ្ទាល់ ឬ ផ្ញើរតាមប៉ុស្តិ៍ អ្នកមិនត្រូវបង់ប្រាក់ទៅអ្នកណាម្នាក់ ក្នុងការជួយបំពេញ ពាក្យសុំនេះទេ ។

**www.dhcs.ca.gov**

បើត្រូវការជំនួយក្នុងការសុំ Medi-Cal ដោយ *មិនបាច់បង់ប្រាក់*
សូមទាក់ទង មកមន្ទីរសង្គមកិច្ច (Welfare Office) នៅជិតអ្នក



របៀបបំពេញ ➡

# តើត្រូវបំពេញពាក្យសុំដូចម្តេច

- ហែកផ្តាច់ពាក្យសុំពី សៀវភៅ
- អានពាក្យសុំឲ្យបានសព្វគ្រប់
- បំពេញពាក្យសុំ ឲ្យបានច្រើនដែលអាចធ្វើបាន
- ដាក់ភ្ជាប់ឯកសារដែលត្រូវការ (សូមអានរបៀបបំពេញ)
- បើត្រូវការជំនួយក្នុងការបំពេញ សូមទាក់ទង មន្ទីរសង្គមកិច្ច នៅជិតអ្នក
- កុំបង្អែរបង្អង់ ក្នុងការផ្ញើរពាក្យសុំនេះ

## តើពត៌មានរបស់អ្នកណាដែលត្រូវចុះនៅក្នុងពាក្យសុំនេះ ?



- បើសិនអ្នកជាមនុស្សចាស់ គ្មានប្តីឬប្រពន្ធ នៅជាមួយ ហើយគ្មានកូន ត្រូវចុះពត៌មានផ្ទាល់ខ្លួនរបស់អ្នក ។
- បើអ្នករៀបការតាមច្បាប់ ហើយរស់នៅជាមួយគ្នា ត្រូវចុះពត៌មានរបស់អ្នក និងប្តីឬប្រពន្ធអ្នក ។
- បើអ្នករៀបការតាមច្បាប់ តែមានម្នាក់ ឬទាំងពីនាក់ ស្នាក់នៅ ណឺស៊ីងហូម (Nursing Home) ឬកន្លែងផ្តល់បន្ទប់ និងម្ហូបអាហារ ត្រូវចុះពត៌មានរបស់អ្នក និងប្តីឬប្រពន្ធអ្នក ។
- បើកូនអ្នកមានអាយុតិចជាង 21ឆ្នាំ ហើយរស់នៅជាមួយអ្នក និង ឪពុកឬម្តាយរបស់គេម្ខាងទៀត ចុះពត៌មានរបស់អ្នកផ្ទាល់ កូនអ្នក និង ឪពុកឬម្តាយរបស់គេម្ខាងទៀត ។
- បើអ្នកមានអាយុតិចជាង 21ឆ្នាំ ហើយមិនរស់នៅជាមួយឪពុកម្តាយចុះពត៌មាន របស់អ្នកផ្ទាល់ ។
- បើអ្នកជាក្មេងមិនទាន់ពេញច្បាប់ មិនទាន់រៀបការ ហើយមានអាយុតិចជាង 21 ឆ្នាំ រស់នៅជាមួយឪពុកម្តាយ តែចង់បានសេវាំសំរាប់លាក់ការសំងាត់ ចុះពត៌មានរបស់ អ្នកផ្ទាល់ ។

## តើមានកើតហេតុយ៉ាងណា ក្រោយពេលដែលខ្ញុំផ្ញើរពាក្យសុំទៅ ?

- មន្ទីរសង្គមកិច្ចនៅជិតអ្នក នឹងផ្តល់ពត៌មានទៅអ្នកវិញ ក្នុងរយៈពេល 10 ថ្ងៃធ្វើការ ថាគេបានទទួលពាក្យសុំរបស់អ្នកហើយ ។ គេនិងផ្តល់ឈ្មោះបុគ្គលិកម្នាក់ ដែលអ្នកអាចទាក់ទង បើចង់ដឹងពត៌មានពិស្តា អំពីពាក្យសុំរបស់អ្នក ។
- អ្នកនឹងទទួលសំណុំឯកសារតូចមួយ ពីខោនធី ដែលមានពត៌មាន បន្ថែមពីកម្មវិធីផ្សេងទៀត ។
- អ្នកអាចទទួល ការស្នើរសុំ ពត៌មានបន្ថែមដែលខោនធី ត្រូវការដើម្បីធ្វើការសំរេចចិត្តលើ សិទ្ធិក្នុងការទទួលរបស់អ្នក ។
- ភាគច្រើនដែលកើតមានឡើង មន្ទីរសង្គមកិច្ចនៅជិតអ្នក នឹងធ្វើការសម្រេចចិត្ត ពីការដែល អ្នកអាចទទួល ឬមិនអាចទទួលផលប្រយោជន៍នេះក្នុងរយៈពេល 45 ថ្ងៃ ហើយផ្តល់ដំណឹងទៅអ្នកវិញដោយលិខិត អំពីការសម្រេចចិត្តនោះ ។ ការសម្រេចចិត្ត លើសិទ្ធិទទួលដោយសាភាពពិការអាចប្រើរយៈពេលរហូត ដល់ទៅ 90 ថ្ងៃ ។
- បើលោកអ្នកត្រូវបានចាត់ទុកថា អាចទទួលសេវាកម្មបាន អ្នកប្រហែលជាអាចជ្រើសរើសគំរោងសុខភាពមួយអាស្រ័យលើខោនធីដែលអ្នករស់នៅ។ សូម្បីតែមុនអ្នកដឹងថា អ្នកមានសិទ្ធិទទួល Medi-Cal ឬអត់ក៏ដោយ នោះអ្នកអាចទូរស័ព្ទទៅ 1-800-430-4263 (ឥតគិតថ្លៃ) ដើម្បីសួរអំពីផែនការសុខភាពដែលមាននៅក្នុងតំបន់របស់អ្នក ហើយសូមសំណុំឯកសារព័ត៌មាន ដ៏មានពាក្យសុំចុះឈ្មោះ។
- បើអ្នកមិនមានសិទ្ធិទទួល Medi-Cal ដែលមិនបាច់បង់ប្រាក់ហើយមានបំណាង ចង់ដាក់ពាក្យសុំក្នុងកម្មវិធី Healthy Families មន្ទីរសង្គមកិច្ចនៅជិតអ្នក អាចបញ្ជូនបន្តរពាក្យសុំទៅកម្មវិធីបាន ។